**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៤០ **អយក.**សណន

# សេចក្ដីណែនាំ
# ស្ដីពី
# ការជ្រើសរើសនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ

សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ដំណើរការនៃការជ្រើសរើសនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អត្រូវអនុវត្តឱ្យបានស្របទៅតាមស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន។ ឆ្នាំសិក្សានីមួយៗគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបំពេញការងាររបស់ខ្លួន ដើម្បីលើកទឹកចិត្ត និងជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ដោយឈរលើមូលដ្ឋាននៃស្តង់ដារវិជ្ជាជីវៈនាយកសាលារៀន និងគ្រូបង្រៀន ។ ក្នុងស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត នូវការងារមួយចំនួនសម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ បន្ថែមលើសេចក្ដីសម្រេចលេខ០៣ អយក.សសរ ចុះថ្ងៃ១៩ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការបង្កើតគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ សម្រាប់ពានរង្វាន់លើកទឹកចិត្តក្នុងសន្និបាតអប់រំដូចខាងក្រោមៈ

## I. សមាសភាពគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ

### ១. សមាសភាពគណៈកម្មការវាយតម្លៃថ្នាក់ជាតិ

- រៀបចំបច្ចុប្បន្នភាពសមាសភាពដោយមានការទទួលស្គាល់តាមរយៈប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា
- សមាជិកអចិន្ត្រៃយ៍មានភារកិច្ចស្នើសុំពេលវេលាសម្រាប់ប្រជុំគណៈកម្មាការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អតាមការចាំបាច់
- ប្រជុំគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ ដើម្បីបំភ្លឺបញ្ហានានាពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការជ្រើសរើសបេក្ខភាពគ្រូបង្រៀនល្អ និងនាយកសាលារៀនល្អ
- ប្រជុំវាយតម្លៃជ្រើសរើសជ័យលាភីថ្នាក់ជាតិនាយកសាលារៀនល្អ៣រូប និងគ្រូបង្រៀនល្អ៥រូបដើម្បីទទួលពានរង្វាន់ថ្នាក់ជាតិ
- ប្រកាសលទ្ធផលទទួលស្គាល់ជាផ្លូវការនៃជ័យលាភីថ្នាក់ជាតិ និងកំណត់កាលបរិច្ឆេទរៀបចំពិធីផ្លូវការសម្រាប់ការប្រគល់ពានរង្វាន់ថ្នាក់ជាតិ ។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

## ២.សមាសភាពគណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត

| | |
|---|---|
| ១. ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត | ប្រធាន |
| ២.អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្តទទួលបន្ទុកបុគ្គលិក | អនុប្រធាន |
| ៣.អនុប្រធានមន្ទីរអេយក រាជធានី ខេត្តទទួលបន្ទុកបឋមសិក្សា និងអប់រំកុមារតូច | សមាជិក |
| ៤. អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្តមធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| ៥. ប្រធានការិ.បឋមសិក្សា និងកុមារតូចនៃមន្ទីរអេយក រាជធានី ខេត្ត | សមាជិក |
| ៦. ប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅនៃមន្ទីរអេយក រាជធានី ខេត្ត | សមាជិក |
| ៧. ប្រធានការិ.អធិការកិច្ច នៃមន្ទីរអេយក រាជធានី ខេត្ត | សមាជិក |
| ៨. ប្រធានការិ.បុគ្គលិក នៃមន្ទីរអេយក រាជធានី ខេត្ត | សមាជិក |
| ៩. ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក | សមាជិក |

ប្រធានដឹកនាំការប្រជុំគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ ដើម្បីធ្វើការជ្រើសរើសបេក្ខភាព នាយក សាលារៀនល្អចំនួន៣រូប និងគ្រូបង្រៀនល្អ៥រូប សម្រាប់ថ្នាក់រាជធានី ខេត្ត។

## ៣.សមាសភាពគណៈកម្មការវាយតម្លៃថ្នាក់ខណ្ឌ ក្រុង ស្រុក

| | |
|---|---|
| ១. ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក | ប្រធាន |
| ២. អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក | អនុប្រធាន |
| ៣. ប្រធានកម្រងសាលារៀន | សមាជិក |
| ៤. នាយកសាលារៀន | សមាជិក |
| ៥. តំណាងសហគមន៍តាមសាលារៀន | សមាជិក |

ប្រធានដឹកនាំការប្រជុំគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ ដើម្បីធ្វើការជ្រើសរើសបេក្ខភាពនាយកសាលារៀនល្អចំនួន៣រូប និងគ្រូបង្រៀនល្អ៥រូប សម្រាប់ថ្នាក់ខណ្ឌ ក្រុង ស្រុក។

## ៤.សមាសភាពគណៈកម្មការវាយតម្លៃថ្នាក់កម្រងសាលារៀន

| | |
|---|---|
| ១. ប្រធានកម្រងសាលារៀន | ប្រធាន |
| ២.អនុប្រធានកម្រងសាលារៀន | អនុប្រធាន |
| ៣. នាយកសាលារៀន | សមាជិក |
| ៤. តំណាងសហគមន៍តាមសាលារៀន | សមាជិក |

ប្រធានដឹកនាំការប្រជុំគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ ដើម្បីធ្វើការជ្រើសរើសបេក្ខភាពនាយកសាលារៀនល្អចំនួន៣រូប និងគ្រូបង្រៀនល្អ៥រូប សម្រាប់ថ្នាក់កម្រងសាលារៀន។

# II. ភារកិច្ចគណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ

## ១.ភារកិច្ចគណៈកម្មការវាយតម្លៃថ្នាក់ជាតិ

គណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អថ្នាក់ជាតិមានភារកិច្ចដូចខាងក្រោមៈ

- ផ្តល់អនុសាសន៍ និងដំណោះស្រាយដល់ថ្នាក់ក្រោមជាតិ
- ជំរុញការអនុវត្តលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អឱ្យមានប្រសិទ្ធភាព (តាមគោលការណ៍ច្បាប់ តម្លាភាព យុត្តិធម៌ និងលទ្ធផលអាចទទួលយកបាន)
- ក្នុងករណីចាំបាច់គណៈកម្មការវាយតម្លៃនាយកសាលារៀនល្អនិងគ្រូបង្រៀនល្អថ្នាក់ជាតិត្រូវចុះពិនិត្យ
- តាមដាន សង្កេត និងជួបសម្ភាសន៍ជាមួយបេក្ខជនជ័យលាភី
- ពិនិត្យ និងសម្រេចលើលទ្ធផលវាយតម្លៃរបស់ថ្នាក់ក្រោមជាតិ (មានកំណត់ហេតុ របាយការណ៍ និងឯកសារពាក់ព័ន្ធ)
- ប្រជុំគណៈកម្មការថ្នាក់ជាតិដើម្បីវាយតម្លៃបេក្ខភាពជ័យលាភី
- សម្រេចជ្រើសរើសជ័យលាភីនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ
- គណៈកម្មការអាចស្នើនូវបេក្ខភាពតាមការចាំបាច់។

## ២.ភារកិច្ចគណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត

- ប្រជុំវាយតម្លៃជ្រើសរើសយកបេក្ខភាពនាយកសាលារៀនល្អ៣រូប និងគ្រូបង្រៀនល្អ៥រូប ថ្នាក់រាជធានី ខេត្ត ក្នុងចំណោមបេក្ខភាពដែលបានជ្រើសរើសមកពីខណ្ឌ ក្រុង ស្រុក ទាំងអស់នៅក្នុងរាជធានី ខេត្ត
- ប្រជុំវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អដែលខណ្ឌ ក្រុង ស្រុក បានផ្ញើមក ដើម្បីជ្រើសរើសអ្នកមានលក្ខណៈសម្បត្តិខ្ពស់ជាងគេសម្រាប់ចុះធ្វើការវាយតម្លៃ
- ប្រជុំវាយតម្លៃ និងធ្វើចំណាត់ថ្នាក់នាយកសាលារៀនល្អ៣រូប និងគ្រូបង្រៀនល្អ៥រូប ហើយផ្ញើបញ្ជីបេក្ខភាព កំណត់ហេតុប្រជុំ របាយកាណ៍ និងលក្ខណវិនិច្ឆ័យផ្ញើមកគណៈកម្មការវាយតម្លៃថ្នាក់ជាតិ។

## ៣.ភារកិច្ចគណៈកម្មការវាយតម្លៃថ្នាក់ក្រុង ស្រុក ខណ្ឌ

- ប្រជុំវាយតម្លៃជ្រើសរើសយកបេក្ខភាពនាយកសាលារៀនល្អ៣រូប និងគ្រូបង្រៀនល្អ៥រូប ថ្នាក់ខណ្ឌ ក្រុង ស្រុក ក្នុងចំណោមបេក្ខភាព ដែលបានជ្រើសរើសមកពីកម្រងសាលារៀនទាំងអស់ក្នុងខណ្ឌ ក្រុង ស្រុក
- ប្រជុំវាយតម្លៃ និងធ្វើចំណាត់ថ្នាក់នាយកសាលារៀនល្អ៣រូប និងគ្រូបង្រៀនល្អ៥រូប ហើយផ្ញើបញ្ជីបេក្ខភាព កំណត់ហេតុប្រជុំ របាយកាណ៍ និងលក្ខណវិនិច្ឆ័យផ្ញើមកគណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត។

## ៤.ភារកិច្ចគណៈកម្មការវាយតម្លៃថ្នាក់កម្រងសាលារៀន

- ប្រជុំវាយតម្លៃជ្រើសរើសយកបេក្ខភាពនាយកសាលារៀនល្អ១រូប និងគ្រូបង្រៀន១រូប នៅគ្រប់សាលារៀនទាំងអស់នៃកម្រងសាលារៀននីមួយៗ
- ប្រជុំវាយតម្លៃ និងធ្វើចំណាត់ថ្នាក់បេក្ខភាពនាយកសាលារៀនល្អ៣រូប និងគ្រូបង្រៀន៥រូប សម្រាប់ថ្នាក់កម្រងសាលារៀនដែលបានជ្រើសរើសហើយផ្ញើបញ្ជីបេក្ខភាព កំណត់ហេតុប្រជុំ របាយកាណ៍ និងលក្ខណវិនិច្ឆ័យផ្ញើមកការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ ក្រុង ស្រុក ។

**បញ្ជាក់៖** គណៈកម្មការវាយតម្លៃនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អថ្នាក់ក្រោមជាតិមានភារកិច្ចរៀបចំកំណត់ហេតុ របាយការណ៍វាយតម្លៃជ្រើសរើសបេក្ខភាពនាយកសាលារៀនល្អ និងគ្រូបង្រៀនល្អ និងឯកសារពាក់ព័ន្ធទាំងអស់ជូនគណៈកម្មការថ្នាក់ជាតិឱ្យបានទាន់ពេល និងគ្រប់ជ្រុងជ្រោយប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំងអស់ត្រូវផ្សព្វផ្សាយសេចក្តីណែនាំនេះដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន សាលារៀនឱ្យបានទូលំទូលាយ និងចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

កន្លែងទទួល៖
- គ្រប់សាលារាជធានី ខេត្ត
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អ.យ.ក «ដើម្បីជូនជ្រាប»
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត «ដើម្បីអនុវត្ត»
- ឯកសារកាលប្បវត្តិ នា. បឋមសិក្សា